**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# ការអន្តរាគមន៍ជួយដល់ពលករខ្មែរនៅប្រទេសអារ៉ាប៊ីសាអូឌីត ឱ្យបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជនជ្រាបថា បន្ទាប់ពីទទួលបានព័ត៌មានអំពីពលករខ្មែរនៅប្រទេសអារ៉ាប៊ីសាអូឌីត ដែលបានស្នើសុំអន្តរាគមន៍ឱ្យពួកគាត់បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការយ៉ាងសកម្មជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសអារ៉ាប៊ីសាអូឌីត ដែលមាននិវេសនដ្ឋាននៅទីក្រុងគែរ ប្រទេសអេហ្ស៊ីប បានរកឃើញទីតាំង និងរៀបចំកន្លែងស្នាក់នៅជាបណ្តោះអាសន្នជូនដល់បងប្អូនទាំងអស់នោះភ្លាមៗ និងរៀបចំឱ្យបងប្អូនប្រជាពលរដ្ឋចំនួន ២៤នាក់ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញដោយសុវត្ថិភាពរួចមកហើយដែរ។ ជានីតិវិធី ប្រទេសទទួលពលករត្រូវបំពេញនីតិវិធីនានាដើម្បីធានាថា ពលករទាំងអស់មិនត្រូវបានរំលោភបំពាននៅក្នុងប្រទេសទទួលឡើយ។ ហេតុដូច្នេះហើយ ទើបតម្រូវឱ្យបងប្អូននៅរង់ចាំទទួលការដោះស្រាយឱ្យបានរួចស្រេចនៅប្រទេសអារ៉ាប៊ីសាអូឌីតសិន។ សម្រាប់បងប្អូនដែលមិនទាន់អាចវិលត្រឡប់មកវិញ គឺត្រូវបានយកចិត្តទុកដាក់ជួយទំនុកបម្រុងក្នុងការហូបចុក និងស្នាក់នៅពីសំណាក់មន្ត្រីរបស់ក្រសួង និងស្ថានឯកអគ្គរាជទូតកម្ពុជា និងបានកំពុងរៀបចំឱ្យបានវិលត្រឡប់មកប្រទេសកម្ពុជាវិញជាដំណាក់ៗ។

ក្រសួងសូមបញ្ជាក់ថា ចាប់តាំងពីថ្ងៃទទួលបានព័ត៌មានអំពីការស្នើសុំរបស់បងប្អូនប្រជាពលរដ្ឋមករាជរដ្ឋាភិបាលកម្ពុជាបានអន្តរាគមន៍ជាបន្ទាន់ ដោយមិនបានទុកបងប្អូនប្រជាពលរដ្ឋចោលនោះទេ និងបានបញ្ជូនមន្ត្រីក្រសួងចំនួន ២រូប ទៅប្រទេសអារ៉ាប៊ីសាអូឌីត ដើម្បីសហការជាមួយឯកឧត្តមឯកអគ្គរាជទូតកម្ពុជាសម្របសម្រួលដោះស្រាយជាមួយនិយោជក និងភាគីពាក់ព័ន្ធក្នុងការរៀបចំនីតិវិធីនានា ដើម្បីបងប្អូនប្រជាពលរដ្ឋបានវិលត្រឡប់មកមាតុប្រទេសវិញបានឆាប់រហ័ស និងមានសុវត្ថិភាព។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។ P. lay

ថ្ងៃ អង្គារ ៧កើត ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០២៤